រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

061KH01A-01

កម្មវិធីសំរាប់បង្រៀនក្រុមជំនុំរបស់អ្នក



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៦១

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ប្រើអ្នក និង គ្រូបង្រៀនទាំងអស់នៅ
ក្នុងក្រុមជំនុំរបស់អ្នក ដើម្បីបណ្តុះបណ្តាលសមាជិកទាំងអស់របស់
ក្រុមជំនុំអ្នក អោយចេះធ្វើកិច្ចការថ្វាយព្រះជាម្ចាស់ ។

ការសិក្សានេះ នឹងជួយអ្នកឱ្យមានគំនិតផ្តួចផ្តើមធ្វើកម្មវិធីបង្រៀន
និង ចេះចាត់ចែងកម្មវិធីនោះ ដែលនឹងនាំអោយសមាជិករបស់
ក្រុមជំនុំអ្នក អាចបំរើព្រះអម្ចាស់ប្រកបដោយប្រសិទ្ធិភាព គឺចេះ
នាំមនុស្សឯទៀតអោយជឿលើព្រះគ្រីស្ត និង យកព្រះអំណោយ
ទានទៅស្អាងក្រុមជំនុំរបស់ព្រះគ្រីស្ត ។

មានកម្មវិធីបង្រៀនច្រើនណាស់ ដែលអ្នកអាចប្រើបាន ។ ប៉ុន្តែ
ការសិក្សានេះជារបៀបបង្រៀនសាមញ្ញ និង មានប្រសិទ្ធិភាព
ដែលអ្នកអាចសំរួលទៅតាមគោលដៅ និង សេចក្តីត្រូវការ
របស់ក្រុមជំនុំអ្នក ។



កំណត់ចំណាំ :

© Project WorldReach © SEAN

កំណត់ចំណាំ :

ផ្នែក ទី ១ :

កំណត់គោលដៅសំរាប់កម្មវិធីបង្កើតសាវ័ក និង កម្មវិធីបង្រៀនរបស់អ្នក

សាវ័កប៉ូលសរសេរថា÷ *«ដូច្នេះ យើងផ្សព្វផ្សាយដំណឹងអំពីព្រះ-គ្រីស្តនេះ ហើយយើងដាស់តឿន និង ប្រៀនប្រដៅមនុស្សគ្រប់ៗរូប ដោយប្រើប្រាជ្ញាគ្រប់យ៉ាង ធ្វើអោយគេទាំងអស់គ្នាបានគ្រប់លក្ខណៈក្នុងអង្គព្រះគ្រីស្ត »* (កូឡូស ១:២៨) ។ គោលដៅចុងបញ្ចប់របស់កម្មវិធីបង្រៀនរបស់ក្រុមជំនុំ គឺធ្វើឱ្យមនុស្សបានគ្រប់លក្ខណ៍ក្នុងអង្គព្រះគ្រីស្ត ។ ប៉ុន្តែ នៅពេលអនុវត្តគោល-ដៅនេះ មនុស្សម្នាក់ៗនឹងអាចសំរេចគោលដៅសំខាន់ៗផ្សេងទៀតជាច្រើន :

- ថ្វាយខ្លួន និង ចូលជាសមាជិកក្រុមជំនុំ/ព្រះសហគមន៍ គឺយល់ដំណឹងល្អ និង ទទួលព្រះយេស៊ូជាព្រះអម្ចាស់ ។ (ការផ្សព្វផ្សាយដំណឹងល្អ)
- រស់នៅដោយប្រតិបត្តិតាមព្រះគ្រីស្ត គឺក្លាយជាសាវ័ក ដែលប្រតិបត្តិតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះគ្រីស្ត ។ (ការបង្កើតសាវ័កជាមូលដ្ឋាន)

- ចូលរួមធ្វើកិច្ចការបំរើ គឺចូលរួមបំពេញកិច្ចការបំរើដែលមានប្រយោជន៍ ដូចជា ការផ្សព្វផ្សាយដំណឹងល្អ ការបង្រៀន ការបំរើ ការផ្តល់ដំបូន្មាន បេសកកម្មគ្រីស្តទូត ។ល។ ។
(អ្នកសិក្សាទាំងអស់ចូលរួមធ្វើកិច្ចការបំរើ)

- បានគ្រប់លក្ខណ៍ក្នុងអង្គព្រះគ្រីស្ត គឺយល់ព្រះគម្ពីរកាន់តែជ្រៅជ្រះ រីកចំរើនឡើងខាងជីវិតគ្រីស្តជន និង ខាងការបំរើព្រះអម្ចាស់ ។
(ការសិក្សា និង អនុវត្តតាមព្រះគម្ពីរ)

ភារៈកិច្ចផ្សេងខ្លះទៀត ដែលអ្នកចាត់ចែងត្រូវបំពេញ ពេលអនុវត្តតាមដំណើរការដែលមានរៀបរាប់រួចមកហើយនេះ :



- ណែនាំពួកអ្នកដឹកនាំក្រុមបង្កើតសាវ័កតូចៗ អោយបង្ហាត់បង្រៀនពួកអ្នកជំនួយ ដើម្បីបង្កើនចំនួនគ្រូបង្រៀន ដែលអាចដឹកនាំក្រុមបង្កើតសាវ័កថ្មីៗបន្ត ។

- ពិនិត្យមើល «តារាងបង្ហាញពីការីកចំរើនរបស់និស្សិតជាសាវ័ក» របស់ពួកអ្នកដឹកនាំក្រុម ដើម្បីអោយដឹងថា ក្រុមផ្សេងៗកំពុងធ្វើសកម្មភាពបង្កើតសាវ័កណាខ្លះ ។

- អធិស្ឋានទូលសូមអោយពួកអ្នកជឿ កាន់តែចេះធ្វើកិច្ចការបំរើ និង ចូលរួមធ្វើកិច្ចការបំរើកាន់តែច្រើន ។

- រៀបចំសកម្មភាពសំរាប់ក្រុមគ្រួសារទាំងមូលៗ ដើម្បីអោយមនុស្សគ្រប់វ័យអាចធ្វើបានរួមគ្នាខ្លះ មិនមែនចេះតែបែកគ្នារហូតទេ ។

គោលដៅបួនសំរាប់កម្មវិធីបង្រៀន

១- ថ្វាយខ្លួន និង ចូលរួមជាសមាជិកក្រុមជំនុំ/ព្រះសហគមន៍ ។
(ការផ្សព្វផ្សាយដំណឹងល្អ)

២- រស់នៅដោយប្រតិបត្តិតាមព្រះគ្រីស្ត
(ការបង្កើតសាវ័កជាមូលដ្ឋាន)

៣- ចូលរួមធ្វើកិច្ចការបំរើ ។
(អ្នកសិក្សាទាំងអស់ចូលរួមធ្វើកិច្ចការបំរើ)

៤- បានគ្រប់លក្ខណ៍ក្នុងអង្គព្រះគ្រីស្ត ។
(ការសិក្សា និង អនុវត្តតាមព្រះគម្ពីរ)

៣- អោយមនុស្សនៅក្នុងក្រុម ទី ១ របស់អ្នក បន្តចែកចាយដំណឹងល្អប្រាប់ក្រុមគ្រួសារ មិត្តភ័ក្តិ និង អ្នកជិតខាងរបស់ពួកគេ ។

៤- ជួយសំរួលអោយមនុស្សនៅក្នុងក្រុម ទី ១ របស់អ្នក អាចចាប់ផ្តើមក្រុមរបស់ពួកគេផ្ទាល់ និង បង្រៀនសមាជិករបស់ក្រុមរបស់ពួកគេរៀងខ្លួន អោយក្លាយជាសាវ័ក ដោយប្រើវិធី ដែលពួកគេបានរៀនហើយ (ការបង្កើតសាវ័កជាមូលដ្ឋាន) ។ ដូច្នេះ នឹងមានក្រុមថ្មីៗកើតឡើងច្រើនទៀត ដូចជាក្រុមទី ២ ទី ៣ ទី ៤ ។

៥- ជូនដំណឹង និង ជំរុញពួកគ្រូបង្រៀន ដែលជាសមាជិកក្រុមទី ១ អោយណែនាំសមាជិករបស់ក្រុមថ្មី ទី ២ ទី ៣ ទី ៤ របស់ពួកគេ ដែលបានរៀនអំពីការបង្កើតសាវ័កជាមូលដ្ឋានហើយ អោយផ្សព្វផ្សាយដំណឹងល្អដល់ក្រុមគ្រួសារ និង មិត្តភ័ក្តិរបស់ខ្លួន និង ចាប់ផ្តើមក្រុមបង្កើតសាវ័កថ្មីរបស់ពួកគេផ្ទាល់រៀងខ្លួន ។ ដូច្នេះ អ្នកនឹងមានក្រុមថ្មីៗទៀត ដូចជាក្រុម ទី ៥ ទី ៦ ទី ៧ ទី ៨ ។

គោលដៅទាំងបួននេះ ប្រៀបដូចជាជីវិត (ការដុះលូតលាស់) របស់ដើមឈើ ដែលគេដាំ ដើម្បីអោយបានផលផ្លែច្រើន :

១- ការសាបព្រោះគ្រាប់ពូជ រហូតដល់ពេលគ្រាប់ពូជចេញពន្លក ។ (ការផ្សព្វផ្សាយដំណឹងល្អ)



២- ពីពេលគ្រាប់ពូជចេញពន្លក ដល់ពេលក្លាយជាសំណាប ។ (ការបង្កើតសាវ័កជាមូលដ្ឋាន)



របៀបចាប់ផ្តើមមួយ (សំរាប់គ្រូគង្វាល ឬ អ្នកចាស់ទុំ ដែលធ្វើកិច្ចការបំរើជាអ្នកចាត់ចែង) ។

១- ក្នុងឋានៈជាអ្នកចាត់ចែង ត្រូវបង្កើតក្រុម ទី ១ ដើម្បីបង្រៀនពួកអ្នកជឿស្មោះត្រង់មួយចំនួនតូច អោយក្លាយជាសាវ័ក (ការបង្កើតសាវ័កជាមូលដ្ឋាន) ។



២- បង្រៀនមនុស្សនៅក្នុងក្រុម ទី ១ របស់អ្នក ពីរបៀបផ្សព្វផ្សាយដំណឹងល្អដល់អ្នកឯទៀត ។ ដំបូង ចេញទៅជាមួយពួកគេ ដើម្បីបង្ហាញពួកគេពីរបៀបចែកចាយដំណឹងល្អប្រកបដោយប្រសិទ្ធិភាព ។

កិច្ចការដែលត្រូវអនុវត្ត

- ជួបប្រជុំជាមួយពួកអ្នកជំនួយរបស់អ្នក ដើម្បីអធិស្ឋាន ប៉ាន់ស្មានអំពីសេចក្តីត្រូវការ និង កំណត់គោលដៅទាំង-ឡាយ សំរាប់ធ្វើអោយកម្មវិធីសំរាប់បង្រៀនក្រុមជំនុំរបស់អ្នក បានប្រសើរឡើង ។
- ធ្វើយ៉ាងណាអោយផែនការរបស់អ្នក អាចធ្វើអោយមនុស្សម្នាក់ៗ មិនគ្រាន់តែទទួលការបង្រៀនប៉ុណ្ណោះទេ តែថែមទាំងបង្កើតសាវ័កទៀតផង ។ (ទោះបីជាការនេះ មានន័យថា ត្រូវអោយនិស្សិតបង្រៀនមេរៀនដែលខ្លួនបានរៀនដល់ក្រុមគ្រួសារ និង មិត្តភ័ក្តិខ្លួនក៏ដោយ) ។
- រៀបចំ (ឬ រៀបចំឡើងវិញ) កម្មវិធីសំរាប់បង្រៀនក្រុមជំនុំអ្នក ស្របទៅតាមគោលដៅ ដែលអ្នកបានកំណត់នេះ ។

៣- ការយកសំណាបទៅដាំនៅក្នុងទីកន្លែងធំទូលាយជាងមុន ដើម្បីឱ្យដើមលូតលាស់ឡើង និង មានផលផ្លែ ។
(កិច្ចការបំរើ)



៤- ដើមដុះធំពេញលេញ និង មានផលផ្លែ ។
(ការសិក្សា និង អនុវត្តតាមព្រះគម្ពីរ)



© Project WorldReach © SEAN

ដំណាក់ការទាំងបួននេះ ចាំបាច់ណាស់ ។ ដំបូង មនុស្សម្នាក់ៗ ត្រូវយល់អំពីដំណឹងល្អសិន ដើម្បីអាចថ្វាយជីវិតរបស់ខ្លួនទៅព្រះ-គ្រីស្ត ។ បន្ទាប់មក ក្នុងដំណាក់ការបង្កើតសាវ័កជាមូលដ្ឋាន ពួកគេចេះរស់នៅតាមជំហានដំបូងៗរបស់ជីវិតគ្រីស្តជន ។ ក្រោយមក ព្រះវិញ្ញាណដ៏វិសុទ្ធនឹងដឹកនាំគេឱ្យចូលរួមធ្វើកិច្ចការបំរើ នៅក្នុងក្រុមជំនុំ តាមអំណោយទានរបស់ពួកគេ ។ ពួកគេរៀនបន្ត ឱ្យស្គាល់ព្រះយេស៊ូគ្រីស្ត និង ព្រះគម្ពីរកាន់តែច្បាស់លាស់ពេញលេញ ដើម្បីបំរើព្រះជាម្ចាស់ ។ មុននឹងបន្តទៅទៀត សូមអាន អេភេសូ ៤:១-១៦ ដើម្បីសិក្សាពីគោលដៅរបស់កម្មវិធីបង្រៀនរបស់ក្រុម-ជំនុំ ។ ឥឡូវនេះ យើងនឹងមើលពីគោលដៅទាំងបួននៅទំព័របន្ត បន្ទាប់ ដោយពិស្តារ ។

ការរៀនសាឡើងវិញ

តើគោលដៅទាំងបួននៃកម្មវិធីសំរាប់បង្រៀនក្រុមជំនុំ សំរាប់អស់អ្នកដែលមកចូលរួមក្នុងក្រុមជំនុំ គឺអ្វីខ្លះ ? ។

© Project WorldReach © SEAN

- កត់ត្រា និង រៀបចំផែនការរួមគ្នាអំពីកិច្ចការ ដែលអ្នកត្រូវធ្វើ ។ បើធ្វើការងារជាក្រុម នោះជាការល្អ ព្រោះសមាជិកចេះចុះចូលគ្នាទៅវិញទៅមក ។ ការងាររបស់ក្រុមបង្កើតសាវ័កអាចទៅសួរសុខទុក្ខតាមផ្ទះ បង្កើតក្រុមផ្សេងទៀតសំរាប់ផ្សាយដំណឹងល្អតាមផ្ទះ ផ្សាយដំណឹងល្អតាមផ្លូវ ។ល។ ។



គោលដៅ ទី ១ :

ថ្វាយខ្លួន និង ចូលជាសមាជិកក្រុមជំនុំ/ព្រះសហគមន៍

(ការផ្សព្វផ្សាយដំណឹងល្អ)

មនុស្សគ្រប់គ្នា ដែលមានទំនាក់ទំនងជាមួយក្រុមជំនុំ ដំបូង ត្រូវស្គាល់ដំណឹងល្អជាចាំបាច់ ។ ហេតុនេះហើយ ទើបដំណាក់ការដំបូងនៃកម្មវិធីបង្រៀនរបស់ក្រុមជំនុំ គឺការផ្សព្វផ្សាយដំណឹងល្អ ។ សមាជិកក្រុមជំនុំទាំងអស់ត្រូវចេះផ្សព្វផ្សាយ និង ពន្យល់ដំណឹងល្អតាមផ្ទះដល់សាច់ញាតិ មិត្តភក្តិ ភ្ញៀវដែលមកព្រះវិហារ អ្នកធ្វើការជាមួយ ឬ នៅគ្រប់កន្លែងដែលគេជួបអ្នកទាំងនោះ ។

សមាជិកម្នាក់ៗសុទ្ធតែមានមនុស្សដែលគេទាក់ទងជាមួយ គឺសាច់ញាតិ និង មិត្តភក្តិ ដែលពួកគេត្រូវចេះផ្សព្វផ្សាយដំណឹងល្អជ្រាប់ ។ ពួកគេបង្រៀនអ្នកទាំងនោះអំពីព្រះយេស៊ូ អំពីការអស្ចារ្យដែលព្រះអង្គធ្វើ អំពីការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ត ថែមទាំងពីរបៀបដែលព្រះអង្គលើកលែងទោសអំពើបាបដោយសារព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ និង ជីវិតអស់កល្បដល់អស់អ្នកដែលកែប្រែចិត្តគំនិត ហើយទទួលជឿ ។

យោបល់អំពីអត្ថបទសិក្សា (រឿងក្នុងព្រះគម្ពីរ) សំរាប់ការផ្សព្វ
ផ្សាយដំណឹងល្អ :

- ការបង្កើត : កំណើតពិភពលោក ជំពូក ១ (ពន្យល់ដែរ
ថា ដោយសារយើងទុកចិត្តលើព្រះគ្រីស្ត ព្រះជាម្ចាស់ធ្វើឱ្យ
យើងមានចំណែកក្នុងការបង្កើតផ្ទៃមេឃថ្មី និង ផែនដីថ្មី
របស់ព្រះអង្គ ២ កូរិនថូស ៥:១៤-២១ និង វិវរណៈ
២១:១-៨ ។ បើអ្នកពន្យល់កុមារ សូមគ្រាន់តែពន្យល់ខ
ទាំងនេះ គឺកុំអានច្រើនពេក ព្រោះនាំអោយកុមារលែងចាប់
អារម្មណ៍) ។

- មនុស្សធ្លាក់ចុះក្នុងអំពើបាប : កំណើតពិភពលោក ជំពូក
៣ (ពន្យល់ដែរថា ដោយសារព្រះគ្រីស្តស្តាប់បង្គាប់ព្រះ-
បិតាព្រះអង្គ ទើបព្រះអង្គក្លាយជា «លោកអាដាមចុង
ក្រោយបង្អស់» ដែលប្រទានអោយយើងមានជីវិតអស់-
កល្ប គឺអោយរួចពីសេចក្តីស្លាប់វិញ រ៉ូម ៥:១២-២១,
១ កូរិនថូស ១៥:៤២-៥៥) ។

- រឿងអំពីលោកណូអេ : កំណើតពិភពលោក ៦:៧-២៤ ។

យោបល់អំពីរបៀបអារៈសំរាប់ការប្រជុំក្រុម

- អធិស្ឋាន និង យកពេលអធិស្ឋានសំរាប់គ្នាទៅវិញទៅមក ។

- ពិភាក្សាពីគោលដៅ ដែលអ្នកបានសំរេចកំណត់យក នៅ
ពេលប្រជុំលើកមុន និង លទ្ធផល (និស្សិតទាំងឡាយរាយ
ការណ៍អំពីកិច្ចការ ដែលពួកគេបានធ្វើ ដើម្បីអនុវត្តតាម
សេចក្តីដែលពួកគេបានរៀននៅក្នុងរយៈពេលចុងក្រោយ) ។
ត្រូវបញ្ជាក់អំពីកិច្ចការដែលបានធ្វើហើយ មិនមែនអំពីសេចក្តី
ដែលគ្រាន់តែបានរៀនដោយប្រាជ្ញាប៉ុណ្ណោះទេ ។ នៅពេល
ប្រជុំចែកចាយបទពិសោធន៍ប្រាប់គ្នា និស្សិតទាំងអស់នឹងរីក
ចំរើនឡើង ដោយសារបានឮបទពិសោធន៍ផ្សេងៗយ៉ាងច្រើន
ដូចនេះ ។

- បង្រៀន ។ គ្រូបង្រៀនដ៏វៃឆ្លាត មិនយកពេលបង្រៀន
មេរៀនយូរពេកទេ តែគាត់ចាប់ផ្តើមបង្រៀនមួយរយៈខ្លី រួច
សួរសំណួរ ដែលជំរុញឱ្យនិស្សិតទាំងអស់ចូលរួមចែកចាយ
យោបល់ ។ គោលដៅនៃការសិក្សាព្រះគម្ពីរ គឺដើម្បីយក
ទៅអនុវត្តតាមក្នុងជីវិត ។

- នៅពេលបង្រៀន សួរសំណួរដើម្បីជួយឱ្យអ្នកសិក្សាទាំងអស់ចូលរួមចំណែកទាំងអស់គ្នា ។ ឧទាហរណ៍ : នៅពេលដែលពួកអ្នកសិក្សា សិក្សា ២ កូរិនថូស ៦:១៤ មិនត្រូវនិយាយថា÷ «បើគ្រីស្តជនទៅរៀបការជាមួយអ្នកមិនជឿនោះជាការខុសឆ្គងហើយ» តែត្រូវសួរពួកគេថា÷ «បើគ្រីស្តជនរៀបការជាមួយអ្នកមិនជឿ តើនឹងបានលទ្ធផលដូចម្តេច ?» ។ បើធ្វើដូច្នេះ ពួកអ្នកសិក្សានឹងរៀបចំចិត្តដើម្បីប្រតិបត្តិតាមសេចក្តីបង្គាប់នេះបានជាង ព្រោះពួកគេបានចូលរួមចំណែកខ្លួនឯងក្នុងការបង្រៀន ដោយឆ្លើយ និងពិភាក្សាអំពីសេចក្តីបង្គាប់នេះ ។

អ្នកជឿម្នាក់ៗ យកសេចក្តីដែលខ្លួនបានរៀន ទៅអនុវត្ត ហើយនិយាយប្រាប់ក្រុមពីកិច្ចការ ដែលគេកំពុងធ្វើ និង បញ្ជាពួកគេ ។



- ការកាត់ទោស ការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអម្ចាស់យេស៊ូ ដែលមានចែងនៅក្នុងគម្ពីរដំណឹងល្អទាំងបួន ។
- រឿងកូនពៅដែលវង្វេងបាត់ : លូកា ១៥:១១-៣២ ។
- មន្ត្រីជាតិអេត្យូពីថ្វាយខ្លួន : កិច្ចការ ៨:២៦-៤០ ។
- ឆ្នាំគុកថ្វាយខ្លួន : កិច្ចការ ១៦:១៦-៣៤ ។
- នំបុ័ងជីវិត : យ៉ូហាន ជំពូក ៦ ។
- ព្រះយេស៊ូប្រោសបុរសខ្មោចចូលនៅកេរ៉ាសា : ម៉ាកុស ៥:១-២០ ។
- លោកប៉ូលថ្វាយខ្លួន : កិច្ចការ ៩:១-១៩ ។

នៅពេលប្រកាសដំណឹងល្អប្រាប់អ្នកណាម្នាក់ ត្រូវជួយអ្នកនោះឱ្យ :

- ចេះនិយាយបញ្ជាក់ពីសេចក្តីពិតសំខាន់បំផុត ដែលថាយើងបានព្រះជាម្ចាស់លើកលែងទោសអំពើបាប ហើយបានទទួលជីវិតអស់កល្ប ដោយសារព្រះគ្រីស្តសុគត និង មានព្រះជន្មរស់ឡើងវិញ ។

- និទានរឿងក្នុងព្រះគម្ពីរប្រាប់ក្រុមគ្រួសាររបស់ពួកគេ ។
- អធិស្ឋាន និង ទន្ទេញ ខ គម្ពីរ ។
- ទទួលជឿ កែប្រែចិត្តគំនិត និង ទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រីស្ត ។

សង្ខេបគោលដៅនៃការផ្សព្វផ្សាយដំណឹងល្អ

ត្រូបង្រៀន :	**និស្សិត :**	**ខ្លឹមសារ :**	**គោលដៅ :**
គ្រីស្តជនទាំង អស់នៅក្នុង ក្រុមជំនុំ ។	មិត្តភ័ក្តិ និង សាច់ញាតិ ដែលមិនទាន់ ជឿ ។	ដំណឹងល្អ ។	ការថ្វាយខ្លួន និង ការចូល ជាសមាជិក ក្រុមជំនុំ ។

អ្នកផ្សាយដំណឹងល្អ ត្រូវធ្វើបញ្ជីមួយសំរាប់កត់ឈ្មោះ និង អាស័យដ្ឋានមនុស្ស ដែលគេបានផ្សាយដំណឹងល្អប្រាប់ហើយ ដើម្បី :

- អធិស្ឋានឱ្យពួកអ្នក ដែលមានឈ្មោះក្នុងបញ្ជីនេះរាល់ថ្ងៃ ។
- កត់ត្រាអត្ថបទសិក្សាដែលបានសិក្សាហើយ ។
- ចែកចាយអំពីការរីកចំរើនរបស់ពួកគេប្រាប់ត្រួតងារ ឬ អ្នកត្រួតពិនិត្យការងាររបស់អ្នកផ្សាយដំណឹងល្អនោះ ។

ក្រុមថ្មីៗសំរាប់អនុវត្តគោលដៅពិសេសៗ

យើងអាចចាប់ផ្តើមក្រុមថ្មីៗសំរាប់មួយរយៈពេល (ដូចជា ៦-៨ អាទិត្យ) សំរាប់សេចក្តីត្រូវការពិសេស ។ ឧទាហរណ៍ ដើម្បីធ្វើវិធីផ្សព្វផ្សាយដំណឹងល្អថ្មីមួយ រៀបចំសំរាប់អាពាហ៍ពិពាហ៍ ជួយគ្នាស្រករក្មេងៗ អប់រំកូនៗ ឬ ជួយខាងបញ្ហាសង្គមកិច្ច ។ល។ ។

ជួយធ្វើអោយនិស្សិតក្នុងក្រុមសិក្សា អាចចូលរួមរៀនសូត្រកាន់តែសកម្ម

- បើសិនជាអាចធ្វើបាន ត្រូវអង្គុយជារង្វង់មូល ។
- ផ្តល់ឱកាសអោយនិស្សិតបញ្ចេញមតិយោបល់ និង សួរសំណួរ ។
- មិននិយាយរឿងសម្ងាត់ ។ បើសិនជាអ្នកណាម្នាក់ចែកចាយអំពីរឿងផ្ទាល់ខ្លួនរបស់គេប្រាប់ក្រុម ក្រុមមិនត្រូវនិយាយបន្តប្រាប់អ្នកក្រៅផ្សេងទៀតជាដាច់ខាត ។

ការងាររបស់គ្រូជំនួយ

គ្រូដែលបង្រៀនព្រះគម្ពីរប្រកបដោយប្រសិទ្ធិភាព នឹងរៀបចំនិស្សិតរបស់គាត់អោយមានសមត្ថភាពអាចបំពេញមុខងារបំរើបាន (អេភេសូ ៤:១១-១៦) ។ ដើម្បីអាចធ្វើដូចនេះបាន គ្រូបង្រៀនច្រើនតែត្រូវរកអ្នកជំនួយអោយជួយបង្រៀន និង ដឹកនាំមុខងារបំរើផ្សេងៗរបស់ក្រុម ។ ពួកអ្នកជំនួយទាំងនេះ ត្រូវជាអ្នកដែលគ្មានក្រុមរបស់ខ្លួនឯងផ្ទាល់ទេ ដើម្បីអោយគេមានពេលទំនេរអាចជួយបាន ។

ការងាររបស់គ្រូជំនួយ គឺ :

- ជួយគ្រូបង្រៀនអោយរៀបចំ និង ជួយបង្រៀន គឺជួយបង្រៀនផ្នែកខ្លះរបស់មេរៀន ជាការល្អ ។
- និយាយណែនាំនិស្សិតម្នាក់ៗដោយផ្ទាល់ ដើម្បីអោយពួកគេម្នាក់ៗអាចអនុវត្តគោលដៅតាមព្រះគម្ពីររៀងៗខ្លួន ។

គោលដៅ ទី ២ :

រស់នៅដោយប្រតិបត្តិតាមព្រះគ្រីស្ត

(ការបង្កើតសាវ័កជាមូលដ្ឋាន)

នៅក្នុងពេលអនុវត្តដំណាក់ការបង្កើតសាវ័កជាមូលដ្ឋាននេះ ពួកអ្នកជឿថ្មីខិតខំសិក្សា ដើម្បីឱ្យក្លាយជាសាវ័កសកម្មរបស់ព្រះយេស៊ូគ្រីស្ត ដែលចេះប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអង្គ ។ គ្រូបង្រៀនជួយអ្នកជឿថ្មីម្នាក់ៗឱ្យអាចនាំមនុស្សឯទៀត មកថ្វាយព្រះអម្ចាស់ ជាពិសេស គឺនាំសាច់ញាតិ និង មិត្តភក្តិរបស់ពួកគេ ។

គ្រូបង្រៀនមានភារៈកិច្ចដ៏ធំ គឺចែកចាយប្រាប់ពួកអ្នកជឿថ្មី អំពីរបៀបរស់នៅប្រចាំថ្ងៃជាមួយព្រះគ្រីស្ត ។ គ្រូបង្រៀនមិនមែនគ្រាន់តែចែកចាយមេរៀនប៉ុណ្ណោះទេ តែពួកគេមានជីវិតរស់នៅជាគំរូដល់សិស្សទៀតផង ។ គ្រូបង្រៀនគ្រប់រូប ជាគំរូសំរាប់អោយសិស្សរបស់ពួកគេធ្វើតាម ។ សាវ័កប៉ុលមានប្រសាសន៍ថា៖*«សូមយកតំរាប់តាមខ្ញុំ ដូចខ្លួនខ្ញុំផ្ទាល់បានយកតំរាប់តាមព្រះគ្រីស្តដែរ»* (១ កូរិនថូស ១១:១) ។ ពួកនិស្សិតរៀនអំពីអ្វីៗ ដែលពួកគេឃើញយើងធ្វើ ឆាប់ចេះជាងអ្វីៗ ដែលយើងគ្រាន់តែនិយាយប្រាប់ ។ យើងមានកិត្តិយស និង ភារៈកិច្ចធ្វើអោយនិស្សិតមើលឃើញព្រះគ្រីស្តក្នុងយើង ហើយធ្វើតាមព្រះអង្គ ។

នៅពេលដែលនិស្សិតចាប់ផ្តើមផ្សព្វផ្សាយដំណឹងល្អដល់មនុស្សឯ-ទៀត គ្រូបង្រៀនត្រូវដឹងអំពីកិច្ចការ ដែលនិស្សិតម្នាក់ៗកំពុងធ្វើ ។ គ្រូបង្រៀនត្រូវស្តាប់ពួកគេប្រាប់ពីបញ្ហា និង ព្រះពរដែលពួកគេបានទទួល ហើយត្រូវផ្តល់ដំបូន្មានលើកទឹកចិត្ត និង អធិស្ឋានសំរាប់ពួកគេ ។

សកម្មភាពនៃការបង្កើតសាវ័កជាមូលដ្ឋាន

ប្រើវគ្គគម្ពីរ ដែលត្រូវនឹងសកម្មភាពនិមួយៗ ដើម្បីពន្យល់ពីសកម្មភាពនោះ ។ សូមអោយនិស្សិតទន្ទេញខគម្ពីរ ដែលនៅក្នុងវង់ក្រចកដូចនេះ «( )» ។ បើគ្រូបង្រៀនគ្មានលទ្ធភាព ឬ ពេលវេលា ដើម្បីបង្រៀននិស្សិតផ្តាល់ឱ្យក្លាយជាសាវ័ក តាមត្រូវការទេ ត្រូវសុំអោយគ្រូបង្រៀនចាត់តាំងអ្នកជំនួយ ដើម្បីឱ្យនិស្សិតម្នាក់ៗបានទទួលការមើលថែតាមត្រូវការ ។ មិនចាំបាច់អនុវត្តសកម្ម-ភាពទាំងឡាយ តាមលំដាប់លេខទេ ។ តែសូមជ្រើសរើសយកសកម្មភាពដើម្បីអនុវត្ត ស្របតាមសេចក្តីត្រូវការ ចំណូលចិត្ត និង ឱកាស ។



© Project WorldReach © SEAN

- ធ្វើបញ្ជីកត់ឈ្មោះនិស្សិតរបស់អ្នក ដើម្បីកត់ត្រាអំពីគោល-ដៅ ដែលពួកគេបានសំរេច ។
- អ្នកត្រូវយកបញ្ជីនេះទៅបង្ហាញអ្នកចាត់ចែងរាល់ខែ ដើម្បីជំរាបអំពីការរីកចំរើន និង បញ្ហា ។
- បណ្តុះបណ្តាលគ្រូជំនួយ ដោយអោយគាត់បង្រៀនផ្នែកខ្លះរបស់មេរៀន (បើធ្វើដូច្នេះ គឺនាំអោយគ្រូជំនួយអាចចេះបង្រៀន) ។

អ្នកដឹកនាំដែលចង់ធ្វើអ្វីៗគ្រប់យ៉ាងដោយខ្លួនឯង ជាអ្នកដឹកនាំដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ។ បើមិនបង្ហាត់បង្រៀនគ្រូជំនួយទេ បានន័យថា ធ្វើអោយក្រុមជំនុំព្រះគ្រីស្តចុះខ្សោយ ។ គ្រូបង្រៀនដ៏វៃឆ្លាត ធ្វើអោយគ្រូជំនួយរបស់គាត់អាចបង្រៀនក្រុមបាន ។ គាត់បង្រៀនពួកគ្រូជំនួយទាំងនោះ អោយអាចក្លាយជាគ្រូបង្រៀនក្រុមថ្មីៗ ឬ ថ្នាក់រៀនថ្មីៗ ។ បើធ្វើដូច្នេះ ក្រុមជំនុំនឹងរីកចំរើនឡើង ។

ក- ទទួលយ៉ើដំណឹងល្អ

(សូមទន្ទេញខដែលនៅក្នុងវង់ក្រចក)

១- កែប្រែចិត្តគំនិតពិត : លូកា ៣:១-១៤ (ខ ១១) ។

២- ដឹងជាក់ថា ខ្លួនជាបុត្រធីតារបស់ព្រះជាម្ចាស់ : យ៉ូហាន ១:១-១៨ (ខ ១២) ។

៣- ស្រឡាញ់ និង ស្តាប់បង្គាប់ព្រះអម្ចាស់ក្នុងគ្រប់កិច្ចការ : យ៉ូហាន ១៥:១-២៧, លូកា ១៤:២៥-៣៥, ២ កូរិនថូស ៥:១៤-១៥ (យ៉ូហាន ១៤:១៥) ។

៤- បានទទួលពិធីជ្រមុជទឹក : ម៉ាថាយ ២៨:១៦-២០ (ខ ១៩-២០) ។

៥- ស្គាល់ព្រះវិញ្ញាណដ៏វិសុទ្ធ : យ៉ូហាន ១៤:១៥-២៦, យ៉ូហាន ១៦:៧-១៥ (រ៉ូម ៥:៥) ។

៦- បានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ : លូកា ១១:៩-១៣ (ខ ១៣) ។

៧- អរព្រះគុណជាប់ជានិច្ច : អេភេសូ ៥:១៨-២០ (ខ ២០) ។

ខ- ធ្វើអោយចរិតលក្ខណៈរបស់យើងក្នុង ព្រះគ្រីស្តរីកចំរើនឡើង

១- បង្កើនចរិតលក្ខណៈដែលនាំអោយមានសុភមង្គលដ៏ពិត ម៉ាថាយ ជំពូក ៥-៧ (ម៉ាថាយ ៥:៣-១០) ។

២- អធិស្ឋានរាល់ថ្ងៃ ព្រមទាំងទូលអង្វរសំរាប់អ្នកដទៃ និង តម អាហារ ដោយគ្មានពុតត្បុត សំរាប់សំណូមពរអធិស្ឋានសំខាន់ៗ : ម៉ាថាយ ៦:៥-១៨, ១ ធីម៉ូថេ ២:១-២ (យ៉ូហាន ១៦:២៤) ។

៣- អាន និង ពិចារណាខគម្ពីរខ្លះៗរាល់ថ្ងៃ : ២ ធីម៉ូថេ ៣:១៤-១៧, ម៉ាថាយ ៤:៤, ទំនុកតម្កើង ១១៩:១-២៤ (២ ធីម៉ូថេ ៣:១៦-១៧) ។

៤- លន់តួសារភាពបាបរបស់ខ្លួន និង មានជីវិតបរិសុទ្ធ : ១ យ៉ូហាន ១:៥-១០ (ខ ៩) ។

៥- ចូលរួមក្នុងពិធីកាច់នំប៉័ង : ១ កូរិនថូស ១១:២៣-២៦ (ខ ២៤-២៥) ។

មូលហេតុដែលនាំអោយបង្កើនចំនួនក្រុមថ្មី

ក្រុមជំនុំរបស់អ្នកនឹងរីកចំរើនកាន់តែខ្លាំង បើសិនជាអ្នកប្រមូលមនុស្សថ្មីអោយចូលជាក្រុមថ្មីៗជាបន្ត ដើម្បីបង្រៀនពួកគេពីជំនឿលើព្រះគ្រីស្ត ។ យើងស្រួលប្រមូលភ្ញៀវ មិត្តភក្តិ និង អ្នកជឿថ្មីអោយចូលជាក្រុមថ្មីៗ ជាងបញ្ចូលពួកគេទៅក្នុងក្រុម ដែលមានពីមុនមកហើយ ។

ការងាររបស់គ្រូបង្រៀន



- អធិស្ឋានទូលសូមឱ្យនិស្សិត ថ្វាយខ្លួន និង រីកចំរើនឡើង ។
- សិក្សាអត្ថបទព្រះគម្ពីរ និង រៀបចំការបង្រៀនជាមុន ។
- និយាយជាមួយនិស្សិតម្នាក់ៗផ្ទាល់ ដើម្បីជួយពួកគេអោយអាចយកសេចក្តីដែលពួកគេបានរៀន ទៅអនុវត្តក្នុងជីវិតពួកគេ (បើសិនជាអ្នកគ្មានពេលសំរាប់ធ្វើកិច្ចការនេះដោយខ្លួនឯងទេ សូមចាត់តាំងគ្រូជំនួយ) ។

គ្រូបង្រៀនខ្លះចូលចិត្តប្រើតែព្រះគម្ពីរប៉ុណ្ណោះ ដើម្បីធ្វើមេរៀនរបស់ខ្លួន ដោយមិនប្រើសៀវភៅផ្សេងទេ ។ ពួកគេអានអត្ថបទព្រះគម្ពីរ (ឬ និទានរឿងក្នុងព្រះគម្ពីរ) បន្ទាប់មក សួរសំណួរអោយនិស្សិតអាចពិភាក្សាគ្នាជាក្រុម ។ ពួកគេអាចសួរសំណួរដូចជា :

- តើអត្ថបទព្រះគម្ពីរនេះ បង្រៀនយើងអំពីសេចក្តីសំខាន់អ្វីខ្លះ ?
- តើព្រះជាម្ចាស់មានព្រះហឫទ័យអោយយើងធ្វើកិច្ចការអ្វី ?
- តើអ្នកមានផែនការដូចម្តេច សំរាប់ធ្វើកិច្ចការនោះ ?
- ហើយធ្វើជាមួយអ្នកណា ?
- នៅពេលណា ? ។

មុននឹងអានអត្ថបទព្រះគម្ពីរវែងមួយ គ្រូបង្ហាត់អាចសូមអោយពួកនិស្សិតកត់ចំណុចសំខាន់ៗ នៅពេលដែលគាត់អាន ។ ឧទាហរណ៍ មុននឹងអានត្រូវប្រាប់អ្នកសិក្សាថា÷ « សូមខិតខំរកមើលកិច្ចការពីរយ៉ាង ដែលប្តីត្រូវធ្វើ នៅពេលយើងអាន អេភេសូ ៥:២៦-៣៣ ជាមួយគ្នា » ។

គ- ប្រកាសដំណឹងល្អដល់មនុស្សឯទៀត

១- ពន្យល់ពីអត្ថន័យនៃការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ត : ១ ពេត្រុស ២:២៤, ១ ពេត្រុស ៣:១៨, កាឡាទី ៣:១៣, រ៉ូម ៤:២៥ (អេភេសូ ២:៦) ។

២- ផ្សព្វផ្សាយដំណឹងល្អអំពីព្រះគ្រីស្តប្រាប់សាច់ញាតិ និង មិត្តភក្តិ : យ៉ូហាន ១:៣៥-៤២, យ៉ូហាន ៣:១៦, រ៉ូម ៣:២៣, រ៉ូម ៥:៨, រ៉ូម ៦:២៣, រ៉ូម ១០:៩, រ៉ូម ១០:១៣ (លូកា ២៤:៤៦-៤៨) ។

៣- ផ្សព្វផ្សាយដំណឹងល្អដល់អ្នកដែលមិនធ្លាប់ស្គាល់ ពេលដែលព្រះជាម្ចាស់ប្រទានឱកាសឱ្យ : កិច្ចការ ៨:២៦-៤០ (កិច្ចការ ១៦:៣១) ។

៤- ជួយក្រុមជំនុំអោយចេះផ្សព្វផ្សាយដំណឹងល្អ ប្រាប់មនុស្សដែលមិនទាន់ឮដំណឹងល្អ : កិច្ចការ ១:៨, កិច្ចការ ៨:១-៨ (ម៉ាថាយ ២៨:១៨-២០) ។

៥- កំណត់រក និង ផ្សាយដំណឹងប្រាប់ក្រុមមនុស្ស ដែលនៅមិនទាន់ស្គាល់ដំណឹងល្អ : កិច្ចការ ១០:១-៤៨, កិច្ចការ ១:៨ (យ៉ូហាន ៤:៣៥) ។

© Project WorldReach © SEAN

៦- ពន្យល់ពីរបៀប ដែលធ្វើអោយក្រុមជំនុំបង្កើនចំនួនបន្ត និង រីកសាយពាសពេញផែនដី : កិច្ចការ ជំពូក ១៣ (កិច្ចការ ១៣:៤៧) ។

ឃ- រស់នៅដោយជោគជ័យ

១- ទូលសូមអោយព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំរាល់ថ្ងៃ : ២ កូរិនថូស ៤:១៦, កាឡាទី ៥:១-២៦ (ខ ២២-២៣) ។

២- ទុកចិត្តលើព្រះជាម្ចាស់ ដែលជាព្រះបិតារបស់យើង និង លើសេចក្តីស្រឡាញ់របស់ព្រះអង្គ : រ៉ូម ៨:២៨-៣៩, ម៉ាថាយ ៦:២៥-៣៤ (ខ ៣៣) ។

៣- មានជីវិតថ្មី និង ខុសផ្សេងពីមុន : អេភេសូ ៤:១-៣, ១៧-២៦, កូឡូស ៣:១-១៧ (ខ ១-៣) ។

៤- ប្រឆាំងទប់ទល់នឹងមារសាតាំង : យ៉ាកុប ៤:១-១០ (ខ ៧) ។

៥- ចូលធ្វើសង្គ្រាមខាងព្រលឹងវិញ្ញាណ : អេភេសូ ៦:១០-២០ (ខ ១២) ។

ជួយគ្រូបង្រៀនរៀបចំមេរៀនមួយអាទិត្យ មុនពេលបង្រៀន ។ ហេតុអ្វីបានជាគ្រូបង្រៀនចាំបាច់ត្រូវរៀបចំមេរៀនទុកជាមុន ? ។

គ្រូបង្រៀនដែលវៃឆ្លាតបង្រៀនមេរៀនរបស់ខ្លួន តម្រូវទៅតាមគោលដៅ និង សេចក្តីត្រូវការរបស់និស្សិតរបស់គាត់ ។ បើសិនជាគាត់បង្រៀន ដោយគ្មានគិតអំពីអ្វីៗដែលកើតឡើងក្នុងក្រុមជំនុំ និង ក្នុងជីវិតរបស់និស្សិត នោះនឹងធ្វើឱ្យនិស្សិតធុញអផ្សុក ហើយធ្វើអោយរាំងស្ទះ មិនឱ្យគេអនុវត្តតាមព្រះបន្ទូលផងដែរ ។ នេះជាមូលហេតុ ដែលនាំអោយគ្រូបង្រៀនត្រូវស្គាល់និស្សិតឱ្យច្បាស់ ដើម្បីអាចអោយព្រះបន្ទូលទាក់ទងនឹងជីវិតរបស់ពួកគេ ។ របៀបងាយស្រួលបំផុតសំរាប់រៀបចំ និង បង្រៀនមេរៀនឱ្យមានប្រសិទ្ធិភាព គឺជ្រើសរើសប្រធានបទ និង អត្ថបទព្រះគម្ពីរ ដោយអធិស្ឋាន ហើយជ្រើសរើសដោយរិះគិតអំពីគោលដៅ និង សេចក្តីត្រូវការរបស់និស្សិត ។

ផ្នែក ទី ៣ :

ការរៀបចំ ការបង្រៀន និង ការអនុវត្តមេរៀន

មេរៀននិមួយៗត្រូវមានបីផ្នែក :

១- **ការរៀបចំ** : គ្រូបង្រៀន និង គ្រូជំនួយត្រូវរៀបចំសំរាប់ការបង្រៀន ។

២- **ការបង្រៀន** : មនុស្សម្នាក់អាចបង្រៀនមេរៀនទាំងមូល ឬ អាចអោយគ្រូជំនួយម្នាក់ៗដឹកនាំមេរៀនមួយផ្នែក ឬ អោយក្រុមទាំងមូលពិភាក្សាគ្នាអំពីមេរៀន ។

៣- **ការអនុវត្ត** : បង្រៀននិស្សិតម្នាក់ៗអោយចេះបំពេញភារកិច្ចដែលត្រូវនឹងមេរៀន ។

មេរៀនត្រូវមានផ្នែកទាំងបីនេះជាដាច់ខាត ព្រោះយើងបង្កើតសាវ័កមិនមែនគ្រាន់តែបង្កើតអ្នកស្តាប់ព្រះបន្ទូលប៉ុណ្ណោះទេ (យ៉ាកុប ១:២២) ។ គ្រូបង្ហាត់ត្រូវដាក់កិច្ចការអនុវត្តអោយនិស្សិតធ្វើរាល់ថ្ងៃអាទិត្យ គឺកិច្ចការដែលស្របនឹងសេចក្តីត្រូវការរបស់និស្សិតផ្ទាល់ ថែមទាំងស្របនឹងសេចក្តីត្រូវការរបស់គ្រួសារគាត់ មិត្តភក្តិរបស់គាត់ និង សមាជិកក្នុងក្រុមកិច្ចការបំរើរបស់គាត់ ។

៦- រួចពីបំណងលោភលន់ខាងលោកីយ៍ ដោយសារព្រះហឫទ័យ ប្រណីសន្តោសរបស់ព្រះជាម្ចាស់ : អេភេសូ ២:១-១០ (ខ ៨-១០) ។

៧- ឈ្នះលើសេចក្តីល្បួង : ម៉ាថាយ ៤:១-១១, ហេប្រឺ ៤:១៤-១៦, ១ យ៉ូហាន ២:១៥-១៧ (១ កូរិនថូស ១០:១៣) ។

៨- ប្រឈមមុខនឹងការប្រឆាំងរបស់លោកីយ៍ : យ៉ូហាន ១៧:១៤-១៨, ម៉ាថាយ ៥:៩-១៦ (កិច្ចការ ៥:២៩) ។

៩- អធិស្ឋាន ទូលសូមអោយព្រះជាម្ចាស់រំដោះពួកអ្នក ដែលនៅក្រោមឥទ្ធិពលរបស់អារក្ស ឬ ទម្លាប់អាក្រក់ : ម៉ាថាយ ៨:២៨-៣២, កិច្ចការ ១៦:១៦-១៨ (កូឡូស ២:១៥) ។

ង- នាំព្រះពរទៅអោយអ្នកដទៃ

១- ប្រើអណ្តាតអ្នកដើម្បីកសាងអ្នកដទៃ : យ៉ាកុប ជំពូក ៣ (ខ ៥-៦) ។

២- បង្ហាញសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ ដោយការប្រព្រឹត្ត : លូកា ១០:២៥-៣៧, ១ កូរិនថូស ១៣:១-១៣ (លូកា ១០:២៧) ។

ច- ធ្វើអោយកម្លាំងចិត្តរីកចំរើន

១- ត្រូវធ្វើជាទាហានដ៏ល្អរបស់ព្រះគ្រីស្ត : ២ ធីម៉ូថេ ២:១-១០ (ខ ១-៣) ។

២- មានអំណរជានិច្ច : ភីលីព ៤:១-៩ (ខ ៤) ។

៣- មានសន្តិភាពជាមួយព្រះជាម្ចាស់ : រ៉ូម ៥:១-៩ (ខ ១) ។

៤- មានជំនឿ : ហេប្រឺ ជំពូក ១១ (ខ ១) ។

៥- ចុះចូលនឹងការវាយប្រដៅរបស់ព្រះជាម្ចាស់ ដោយចិត្តអត់-ធ្មត់ : ហេប្រឺ ១២:១-១១ (ខ ១-២) ។

៦- ចាត់ទុកអ្នកឯទៀតៗថា ប្រសើរជាងខ្លួន : ភីលីព ២:១-១១ (១ ពេត្រុស ៥:៦-៧) ។

របៀបរៀបចំការបង្រៀនក្នុងក្រុមជំនុំ មានច្រើនណាស់ ។ នៅទំព័រមុន មានឧទាហរណ៍មួយអំពីរបៀបរៀបចំការបង្រៀន នៅក្នុងក្រុមជំនុំ ដែលអ្នកអាចយកទៅអនុវត្ត ឬ យកទៅសំរួល តម្រូវទៅតាមស្ថានភាពរបស់ក្រុមជំនុំអ្នក ។ ដើម្បីឱ្យនិស្សិតទាំងអស់ក្នុងក្រុមរៀនចេះ ហើយចូលរួមយ៉ាងសកម្មធ្វើការងាររបស់ក្រុម យើងខ្ញុំសូមទូន្មានថា ក្រុមមិនត្រូវមានសមាជិកលើសពីដប់ពីរនាក់ទេ ។ បើសិនជាមានមនុស្សលើសពីដប់ពីរនាក់ ត្រូវបង្កើតក្រុមមួយទៀត ។

ក្រុមនិមួយៗអាចមានបុរស ស្ត្រី មនុស្សពេញវ័យ និង យុវជន ។ ខិតខំអោយក្រុមគ្រួសារបាននៅក្នុងក្រុមជាមួយគ្នា បើអាចធ្វើបាន ។ បើអាចយកពេលវេលាមួយផ្នែកសំរាប់បង្រៀនពិសេសដល់កុមារ និង យុវជន នោះមានប្រយោជន៍ណាស់ ។ ការធ្វើដូចនេះ នាំអោយអាចបង្រៀនស្របទៅតាមសេចក្តីត្រូវការរបស់ក្រុមកុមារ ឬ ក្រុមយុវជន ទៅតាមអាយុរបស់ពួកគេ ។

© Project WorldReach © SEAN

រចនាសម្ព័ន្ធនៃការបង្រៀនក្នុងក្រុមជំនុំ



៧- សំរុះសំរួលជាមួយអ្នកដទៃ : ម៉ាថាយ ៥:២៣-២៤, ១៨:១៥-២២ (អេភេសូ ៤:៣២) ។

៨- លះបង់ចោលអបិយជំនឿ : ទុតិយកថា ១៨:៩-២២, កិច្ចការ ១៩:១៨-២០ (ខ ១៩) ។

៩- ប្រឈមមុខនឹងសេចក្តីស្លាប់ ដោយគ្មានតក់ស្លុត : ១ ថេស្សាឡូនិក ៤:១៣-១៨ (ខ ១៤) ។

១០- រស់នៅអោយស្របតាមព្រះវិញ្ញាណព្រះជាម្ចាស់ : កាឡាទី ៥:១៦-២៥ (កូឡូស ៣:៥) ។

១១- ចេះមើលស្គាល់កិច្ចការរបស់ព្រះវិញ្ញាណព្រះជាម្ចាស់ : រ៉ូម ៨:៥-១៦ (ខ ១៦) ។

ឆ- ធ្វើអោយគ្រួសារអ្នកបានប្រសើរឡើង

១- រក្សាទំនាក់ទំនងល្អជាមួយគូស្រករខ្លួន : សុភាសិត ២២:៦, សេរីភាព ២០:១២, ចោទិយកថា ៦:១-៧ (អេភេសូ ៦:៤) ។

២- បង្រៀន និង ជីកនាំកូនរបស់អ្នក : សុភាសិត ២២:៦ (អេភេសូ ៦:៤) ។

ជ- បំរើអ្នកដទៃ

១- ដាក់ដង្វាយ ដោយចិត្តសប្បុរស : ម៉ាថាយ ៦:១-៤, ១ កូរិនថូស ៩:៦-៨ (ខ ៧) ។

២- ប្រើអំណោយទានផ្សេងៗដែលអ្នកបានទទួល ដើម្បីបំរើព្រះជាម្ចាស់ និង មនុស្សឯទៀត : ១ ពេត្រុស ៤:១០-១១, រ៉ូម ១២:១-៨, ១ កូរិនថូស ១២:១-១៣, អេភេសូ ៤:៧-១៦ (១ ពេត្រុស ៤:១០) ។

ប្រើតារាងនៅទំព័របន្ទាប់ ដើម្បីកត់ឈ្មោះនិស្សិត និង ដាក់លេខសកម្មភាពទាំងឡាយ ដែលមានរៀបរាប់រួចមកហើយនៅទំព័រមុនៗនេះ ពីក្រោមឈ្មោះនិស្សិត ។ សូមកត់ឈ្មោះនិស្សិតម្នាក់ៗ និង លេខសកម្មភាព នៅលើទំព័រមួយៗផ្សេងពីគ្នា ។ សូមកត់សំគាល់ថា ខទាហរណ៍ទីមួយមានគូរបន្ទាត់ពីក្រោមលេខមួយចំនួន ។

ការសិក្សាករណីមួយ : ក្រុមជំនុំ ដែលនៅក្នុងខទាហរណ៍ ខាងលើនេះ បង្ហាត់បង្រៀនគ្រូបង្រៀនរបស់គេ តាមវគ្គសិក្សាពិសេសមួយ ដែលសំរាប់តែគ្រូបង្រៀនប៉ុណ្ណោះ នៅរាល់ខែសីហាមុន នឹងចាប់ផ្តើមសាលាព្រះគម្ពីរ ។ គ្រូគង្វាលដឹកនាំក្រុមជំនុំ ត្រួតពិនិត្យកិច្ចការបំរើរបស់គ្រូបង្រៀនទាំងនោះ និង ត្រៀមខ្លួនជានិច្ចចាំផ្តល់ដំបូន្មានដល់ពួកគេ ។

សូមពិនិត្យមើលខទាហរណ៍តនៅទំព័របន្ទាប់នេះ ។

តារាងបង្ហាញពីការរីកចំរើនរបស់និស្សិតជាសាវ័ក

បើអាចធ្វើបាន សូមថតចម្លងបញ្ជី «សកម្មភាពបង្កើតសាវ័កជាមូលដ្ឋាន» ខាងលើនេះ សំរាប់គ្រូបង្រៀនរបស់អ្នក និង ពួកអ្នកជំនួយរបស់គាត់ ។ បន្ថែមចំណងជើងនៃសម្មភាពដែលអ្នកត្រូវការនៅក្នុងសហគមន៍របស់អ្នក ទៅក្នុងបញ្ជីសកម្មភាពថែមទៀត ។ មួយវិញទៀត សូមថតចម្លង «តារាងបង្ហាញការរីកចំរើនរបស់និស្សិតជាសាវ័ក» នៅទំព័រ ទី ២៤ ដើម្បីកត់ត្រាការរីកចំរើនរបស់និស្សិតម្នាក់ៗ ។ គ្រូបង្រៀនត្រូវសរសេរឈ្មោះនិស្សិតរបស់គាត់ នៅក្នុងតារាង ។ នៅពេលដែលនិស្សិតចាប់ធ្វើសកម្មភាពមួយ និង ទន្ទេញខគម្ពីរ នៅក្នុងវង់ក្រចកហើយ សូមគូសបន្ទាត់ក្រោមលេខសកម្មភាព ដែលនៅក្រោមឈ្មោះនិស្សិតនោះ ។ តារាងដំបូង នៅទំព័របន្ទាប់នេះ ជាឧទាហរណ៍អំពីនិស្សិតម្នាក់ ឈ្មោះភាព ដែលចាប់ផ្តើមធ្វើសកម្មភាព ក-១, ក-២, ក-៣, ខ-៤, និង គ-១ ។

ជ្រើសយក និង រៀបចំសំភារៈ

ជ្រើសយក និង រៀបចំសំភារៈ ដែលត្រូវនឹងកិរិតចាស់ទុំខាងព្រលឹងវិញ្ញាណរបស់ក្រុមអ្នក សេចក្តីត្រូវការ និង ផែនការរបស់ក្រុមអ្នក ។

អ្នកអាចធ្វើ «ការបង្កើតសាវ័កជាមូលដ្ឋាន» បាន កាន់តែប្រសើរដោយប្រើព្រះគម្ពីររបស់អ្នក ព្រមជាមួយគោលការណ៍ណែនាំទាំងឡាយ នៅក្នុងអត្ថបទសិក្សានេះ ។ គ្រូបង្រៀនដែលមានបទ-ពិសោធន៍ ច្រើនតែបង្រៀនកាន់តែល្អ បើគាត់រៀបចំមេរៀនខ្លួនគាត់ ។

បង្ហាត់បង្រៀនពួកគ្រូបង្រៀនរបស់អ្នក

គ្រូបង្រៀនព្រះគម្ពីរពិត បង្ហាត់បង្រៀនគ្រូបង្រៀនថ្មីៗ ដូចជាព្រះអម្ចាស់យេស៊ូគ្រីស្ត និង ពួកសាវ័កព្រះអង្គដែរ ។ ត្រូវបង្ហាត់បង្រៀនពួកគេ ដោយដាក់ភារៈកិច្ចបង្រៀនអោយពួកគេធ្វើកាន់តែច្រើនឡើងៗ ដើម្បីឱ្យពួកគេអាចបង្កើតក្រុមរបស់គេផ្ទាល់ ។ សូមប្រើសៀវភៅនេះ ដើម្បីបង្ហាត់បង្រៀនពួកគេ ។

ឈ្មោះ លោក ភាព

ក	១	២	៣	៤	៥	៦	៧				
ខ	១	២	៣	៤	៥						
គ	១	២	៣	៤	៥	៦					
ឃ	១	២	៣	៤	៥	៦	៧	៨	៩		
ង	១	២									
ច	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
ឆ	១	២									
ជ	១	២									

ផ្នែក ទី ២ :

ការរៀបចំការបង្រៀនក្នុងក្រុមជំនុំ

ក្រុមជំនុំអាចអនុវត្តសកម្មភាពទាំងឬនខាងក្រោមនេះ ដើម្បីរៀបចំធ្វើការបង្រៀនក្នុងក្រុមជំនុំ :

បង្កើតសាលាព្រះគម្ពីររបស់ក្រុមជំនុំ (ឬ កែប្រែ « សាលាថ្ងៃអាទិត្យ »ដែលមានរួចមកហើយ) ទៅតាមគោលការណ៍ណែនាំអំពីការបង្កើតសាវ័ក នៅក្នុងសៀវភៅនេះ

រៀបចំធ្វើតារាងពេលវេលា

ឧទាហរណ៍ពិតជាក់ស្តែង : មានក្រុមជំនុំមួយបានរៀបចំធ្វើតារាងពេលវេលាមួយសំរាប់មុខវិជ្ជាទាំងឡាយ ដោយមានជាក់កាល-បរិច្ឆេទចាប់ផ្តើម និង កាលបរិច្ឆេទបញ្ចប់នៃមុខវិជ្ជានិមួយៗ និង កាលបរិច្ឆេទនៃការប្រឡងរបស់មុខវិជ្ជានិមួយៗ ។ នៅក្នុងសាលាព្រះគម្ពីររបស់ក្រុមជំនុំនេះ ការសិក្សាចាប់ផ្តើមនៅខែកញ្ញា ហើយបន្តពេញមួយខែវិច្ឆិកា ។ ពួកនិស្សិតសំរាកមួយខែ នៅខែធ្នូ និង ចាប់ផ្តើមសិក្សាបន្ត នៅខែមករា ។ ការសិក្សាត្រូវបញ្ចប់ នៅខែមិថុនា ដោយ « ពិធីប្រគល់សញ្ញាបត្រ » ។

សង្ខេបគោលដៅបានគ្រប់លក្ខណ៍ក្នុងអង្គព្រះគ្រីស្ត

គ្រូបង្រៀន :	**និស្សិត :**	**ខ្លឹមសារ :**	**គោលដៅ :**
គ្រីស្តជនចាស់	សាវ័កដែល	ការអនុវត្ត	កែប្រែលោកីយ៍
ទុំខាងព្រលឹង	កំពុងរីកចំរើន	តាមព្រះគម្ពីរ	ដែលនៅជុំវិញ
វិញ្ញាណដែល	ក្នុងព្រះគ្រីស្ត	ក្នុងគ្រប់ផ្នែក	យើង ដោយ
ធ្វើជាគំរូអំពី	និង ដែល	នៃជីវិត ។	មានជីវិតដែល
ជីវិតគ្រីស្តជន	បានចូលរួម		បង្ហាញថា
ពិត ។	ធ្វើកិច្ចការ		ព្រះគ្រីស្តគង់
	បំរើហើយ ។		ក្នុងយើង ។



« តារាងបង្ហាញការរីកចំរើនរបស់និស្សិតជាសាវ័ក »

ឈ្មោះ_____

ក	១	២	៣	៤	៥	៦	៧				
ខ	១	២	៣	៤	៥						
គ	១	២	៣	៤	៥	៦					
ឃ	១	២	៣	៤	៥	៦	៧	៨	៩		
ង	១	២									
ច	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
ឆ	១	២									
ជ	១	២									

ឈ្មោះ_____

ក	១	២	៣	៤	៥	៦	៧				
ខ	១	២	៣	៤	៥						
គ	១	២	៣	៤	៥	៦					
ឃ	១	២	៣	៤	៥	៦	៧	៨	៩		
ង	១	២									
ច	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
ឆ	១	២									
ជ	១	២									

© Project WorldReach © SEAN

សង្ខេបគោលដៅបង្កើតសាវ័កជាមូលដ្ឋាន

គ្រូបង្រៀន :	**និស្សិត :**	**ខ្លឹមសារ :**	**គោលដៅ :**
ឪពុកម្តាយ ឬ	អ្នកដែលជឿ	សេចក្តីបង្គាប់	ចេះប្រតិបត្តិ
អ្នកដែលអាច	ថ្មី ឬអ្នក	និង សេចក្តី	តាមព្រះគ្រីស្ត ។
បង្កើតសាវ័ក	ដែលមិនទាន់	បង្រៀនរបស់	
ឬ គ្រូ ។	រៀនឱ្យក្លាយ	ព្រះគ្រីស្ត ។	
	ជាសាវ័ក ។		



ខព្រះគម្ពីរដប់ពីរ សំរាប់ទន្ទេញលើក ទី ១១

អេសាយ ៤១:១០	សុភាសិត ២៩:២៥
ម៉ាកុស ៨:៣៨	លូកា ១២:៤-៥
យ៉ាកុប ៤:៤	១ ធីម៉ូថេ ២:១-៥
ម៉ាកុស ៨:៣៦	ម៉ាថាយ ៦:៣៣
ភីលីព ៤:១៩	ទំនុកតម្កើង ៣៧:២៥
១ កូរិនថូស ១៣	ទំនុកតម្កើង ១៩

ខព្រះគម្ពីរដប់ពីរ សំរាប់ទន្ទេញលើក ទី ១២

ហេប្រឺ ១២:១៤	យ៉ូហាន ១៤:២៧
ទំនុកតម្កើង ៣៤:១០	ម៉ាថាយ ៧:១
រ៉ូម ២:១-៣	រ៉ូម ១៤:១២
ម៉ាថាយ ៦:១៤-១៥	ភីលីព ៤:១៣
អេភេសូ ៣:២០-២១	ម៉ាថាយ ១៨:៣៤-៣៥
ទំនុកតម្កើង ៨៤	ទំនុកតម្កើង ៦៣

ខព្រះគម្ពីរដប់ពីរ សំរាប់ទន្ទេញលើក ទី ៩

ម៉ាកុស ៧:២១-២៣	រ៉ូម ៣:១២
រ៉ូម ៥:១២	វិវរណៈ ២១:៨
ម៉ាថាយ ២៥:៤១	២ ពេត្រុស ៣:៩
លូកា ១៩:១០	១ យ៉ូហាន ៤:១០
អេភេសូ ១:៧	កូឡូស ១:២០
ទំនុកតម្កើង ៨	ទំនុកតម្កើង ១៩

ខព្រះគម្ពីរដប់ពីរ សំរាប់ទន្ទេញលើក ទី ១០

រ៉ូម ៥:១៩	កិច្ចការ ១៧:៣០-៣១
យ៉ូហាន ៣:៣៦	រ៉ូម ៦:៤
ហេប្រឺ ១០:២៥	ម៉ាកុស ៥:១៩
អេសាយ ១:១៨	១ ធីម៉ូថេ ១:១៥
រ៉ូម ៥:៦-៨	២ ធីម៉ូថេ ១:១២
ទំនុកតម្កើង ៤២	ទំនុកតម្កើង ២

គោលដៅ ទី ៣ :

ចូលរួមធ្វើកិច្ចការបំរើ

(អ្នកសិក្សាទាំងអស់ចូលរួមធ្វើកិច្ចការបំរើ)

យោងទៅតាម ១ កូរិនថូស ១២:៤-៧ អ្នកជឿម្នាក់ៗត្រូវចូលរួមធ្វើកិច្ចការបំរើណាមួយ *«ព្រះវិញ្ញាណប្រោសប្រទានអោយម្នាក់ៗ សំដែងព្រះអំណោយទាន ដើម្បីជាប្រយោជន៍រួម»* ។ គ្រីស្តជនម្នាក់ៗ សុទ្ធតែមានអំណោយទាន ហើយគ្រូបង្រៀនត្រូវជួយគាត់ឱ្យអាចប្រើប្រាស់អំណោយទានទាំងនោះ ក្នុងកិច្ចការបំរើមួយ ។

ក្រុមជំនុំដែលឈ្លាសវៃ តែងតែបើកវគ្គបង្ហាត់បង្រៀនសមាជិកអោយអាចបំពេញកិច្ចការបំរើរបស់ពួកគេរៀងខ្លួន ប្រកបដោយប្រសិទ្ធិភាព ។ វគ្គបង្ហាត់បង្រៀននិមួយៗ ត្រូវរួមបញ្ចូល :

- សេចក្តីផ្តើមដែលណែនាំអ្នកសិក្សាទៅរកកិច្ចការបំរើមួយ ។
- ការបង្ហាត់បង្រៀនឱ្យអ្នកសិក្សាចាប់ផ្តើម និង បន្តបំពេញកិច្ចការបំរើនោះ ដោយអោយអានអត្ថបទព្រះគម្ពីរ ដែលទាក់ទងនឹងកិច្ចការបំរើនោះ និង អត្ថបទផ្សេងទៀតដែលមានប្រយោជន៍សំរាប់កិច្ចការបំរើនោះផង ។

© Project WorldReach © SEAN

- ការបញ្ជាក់អំពីតំរិយាបថនៃសេចក្តីស្រឡាញ់ ជំនឿ និង សេចក្តីសង្ឃឹម ដើម្បីឱ្យអ្នកសិក្សាអាចរីកចំរើនក្នុងកិច្ចការបំរើ ។
- នៅពេលហាត់ធ្វើកិច្ចការបំរើ បង្រៀនអំពីការអនុវត្តដោយ :
  - អធិស្ឋាន និង រៀបចំផែនការជាមួយគ្នា
  - ពិភាក្សាគ្នាអំពីបញ្ហា និង ដំណោះស្រាយ
  - វាយតម្លៃការរីកចំរើន ។



ខព្រះគម្ពីរដប់ពីរ សំរាប់ទន្ទេញលើក ទី ៧

១ កូរិនថូស ១៥:៥៥-៥៨	រ៉ូម ៨:២៦-២៧
រ៉ូម ៨:៣៨-៣៩	យ៉ូហាន ២០:៣០-៣១
១ ធីម៉ូថេ ៤:១-៣	វិវរណៈ ២២:១៩
យ៉ាកុប ៤:១៣-១៥	សុភាសិត ២៧:១
ហេប្រឺ ៩:២៧-២៨	ម៉ាថាយ ២៤:៤៤
សុភាសិត ១៤:១២	ម៉ាថាយ ៧:១៣-១៤

ខព្រះគម្ពីរដប់ពីរ សំរាប់ទន្ទេញលើក ទី ៨

ហេប្រឺ ២:៣	យ៉ូហាន ៣:៣-៦
រ៉ូម ៨:១៦	១ យ៉ូហាន ៤:១៣
១ យ៉ូហាន ៣:១៤	១ យ៉ូហាន ៥:១៣
ម៉ាថាយ ២៨:៦	១ កូរិនថូស ១៥:៣-៦
ទំនុកតម្កើង ៥១:៥	រ៉ូម ៣:៩-១១
ទំនុកតម្កើង ២៣	ទំនុកតម្កើង ១

ខព្រះគម្ពីរដប់ពីរ សំរាប់ទន្ទេញលើក ទី ៥

យ៉ូហាន ៤:១៣-១៤	២ កូរិនថូស ៥:២០-២១
ហេប្រឺ ៩:២៤-២៦	យ៉ូហាន ៧:៣៧-៣៩
អេសាយ ៨:២០	យ៉ូហាន ១២:៤៨
សុភាសិត ៣:៥-៦	រ៉ូម ៦:១-២
១ យ៉ូហាន ៤:១៦	អេសាយ ៤៣:២៥
ម៉ាថាយ ២១:២២	ម៉ាថាយ ៥:២០

ខព្រះគម្ពីរដប់ពីរ សំរាប់ទន្ទេញលើក ទី ៦

រ៉ូម ១០:១២-១៣	រ៉ូម ៨:១៤-១៥
១ ថេស្សាឡូនិក ២:១៣	យ៉ាកុប ១:២១-២២
អេសាយ ២៦:៣-៤	១ កូរិនថូស ១១:២៦
១ កូរិនថូស ៨:៩-១១	ភីលីព ៣:៧-១១
យ៉ាកុប ១:៥-៦	រ៉ូម ៣:២៣-២៦
២ ធីម៉ូថេ ១:៧-៨	សុភាសិត ១២:១៥

ឧទាហរណ៍អំពីកិច្ចការបំរើ

មនុស្សនៅក្នុងក្រុមនិមួយៗ ត្រូវធ្វើកិច្ចការបំរើផ្សេងៗគ្នា ដូចមានបង្ហាញនៅក្នុង ១ កូរិនថូស ជំពូក ១២ ។ កិច្ចការបំរើទាំងនេះខ្លះ ត្រូវសំរាប់តែកន្លែងប្រភេទខ្លះប៉ុណ្ណោះ ។ កិច្ចការបំរើទាំងនេះគ្រាន់តែជាយោបល់ប៉ុណ្ណោះ ។

- ការផ្សព្វផ្សាយដំណឹងល្អ ។
- ការបង្កើតក្រុមជំនុំថ្មី នៅក្នុងទីកន្លែងផ្សេងៗទៀត ។
- ការបង្រៀនកុមារ ។
- ការជួយរំដោះមនុស្សអោយអាចរួចពីការប្រមឹកស្រា និងការញៀនគ្រឿងញៀន ។
- ការធ្វើកិច្ចការបំរើសំរាប់មនុស្សខ្វាក់ មនុស្សថ្លង់ ឬ មនុស្សពិការផ្សេងៗទៀត ។
- ការសំដែងរឿងក្នុងព្រះគម្ពីរជាឆាកល្ខោន ដើម្បីផ្សាយដំណឹងល្អ ឬ កសាងក្រុមជំនុំអោយរីកចំរើនឡើង ។
- ការចូលរួមធ្វើសកម្មភាពសង្គមកិច្ច ។

- ការអធិស្ឋាន និង ធ្វើសង្គ្រាមខាងព្រលឹងវិញ្ញាណតយុទ្ធ នឹងខ្មាំងសត្រូវ ។
- ការណែនាំជំរុញក្រុមជំនុំ ឱ្យធ្វើសកម្មភាពសំរាប់បេសកកម្ម គ្រីស្តទូតនៅបរទេស ដូចជាប្រមូលពត៌មាន និង ថវិកា ព្រមទាំងបង្ហាត់បង្រៀន និង ចាត់ក្រុមគ្រីស្តទូត ។
- ការបណ្តុះបណ្តាលយុវជន អោយបំពេញមុខងារបំរើ ។
- ការធ្វើកិច្ចការបំរើសំរាប់អ្នកដែលទើបនឹងរៀបការថ្មី ។
- ការធ្វើកិច្ចការបំរើសំរាប់មនុស្សចាស់ ។
- ការទៅសួរសុខទុក្ខអ្នកជំងឺនៅផ្ទះ ឬ នៅមន្ទីរពេទ្យ ។
- ការផ្សព្វផ្សាយដំណឹងល្អនៅក្នុងមន្ទីរឃុំឃាំង ។
- ការទៅសួរសុខទុក្ខក្មេងកំព្រា ។
- ការសាងសង់ លំអ ឬ សំអាតកន្លែងប្រជុំ ។
- ការថែរក្សាសួនច្បាររបស់ព្រះវិហារ (បើសិនជាព្រះវិហារ មានសួនច្បារមួយ) ។

ខព្រះគម្ពីរដប់ពីរ សំរាប់ទន្ទេញលើក ទី ៣

ហេប្រឺ ១0:១៤
កិច្ចការ ១៣:៣៨-៣៩
លូកា ២៤:៤៥-៤៧
១ កូរិនថូស ២:៩
១ កូរិនថូស ២:១៤
ទំនុកតម្កើង ១៩:៧
ទំនុកតម្កើង ៣២:៥
រ៉ូម ៨:៣២
កិច្ចការ ១0:៤២-៤៣
វិវរណៈ ១៤:១៣
យ៉ូហាន ១:១២-១៣
យេរេមី ២៩:១៣

ខព្រះគម្ពីរដប់ពីរ សំរាប់ទន្ទេញលើក ទី ៤

រ៉ូម ១:១៦-១៧
ពេត្រុស ៣:១២
ទុតិយកថា ៦:៤-៧
រ៉ូម ១២:១-២
រ៉ូម ៣:១៩-២0
យេរេមី ៣៣:៣
យ៉ូហាន ១0:២៧-២៨
ទុតិយកថា ៤:២
អេសាយ ៤២:៨
២ កូរិនថូស ៩:៨
២ កូរិនថូស ៦:១៧-១៨
ម៉ាថាយ ១៨:១៩

ខគម្ពីរដប់ពីរ សំរាប់ទន្ទេញលើក ទី ១

យ៉ូហាន ១៤:៦	ម៉ាថាយ ១១:២៨-៣០
២ កូរិនថូស ៥:១៧	អេភេសូ ២:៨-១០
កិច្ចការ ៤:១២	ហេប្រឺ ៧:២៥
ម៉ាថាយ ៧:១៣-១៤	រ៉ូម ៨:១
លូកា ២៣:៤២-៤៣	យេរេមី ១៧:៩-១០
១ កូរិនថូស ១:១៨	១ កូរិនថូស ៦:១៩-២០

ខគម្ពីរដប់ពីរ សំរាប់ទន្ទេញលើក ទី ២

យ៉ូហាន ១៥:៤-៥	កាឡាទី ៣:២២
១ ពេត្រុស ៥:៦-៧	យ៉ូហាន ៥:២៤
ម៉ាថាយ ១៨:៣	វិវរណៈ ៣:២០
ហេប្រឺ ៤:១៥-១៦	យ៉ាកុប ៤:៤
ម៉ាថាយ ២២:២៩	អេសាយ ៥៥:១
២ ពេត្រុស ១:២១	រ៉ូម ១០:៩

- ការផ្តល់ដំបូន្មាន ទៅសួរសុខទុក្ខ និង ណែនាំសមាជិកដែលមានបញ្ហាផ្ទាល់ខ្លួន ឬ បញ្ហាគ្រួសារ ។
- ការបង្រៀនអោយចេះអាន និង ចេះសរសេរ ។
- ការបង្រៀនពីអនាម័យ របៀបហូបចុកចំណីអាហារ និង របៀបដាំដំណាំសំរាប់ធ្វើជាម្ហូបអាហារ ដែលមានជីវជាតិ ។
- ការដឹកនាំពិធីថ្វាយបង្គំ និង ផ្គត់ផ្គង់អោយមានតន្ត្រីត្រឹមត្រូវសំរាប់ពិធីថ្វាយបង្គំ ។
- ការជួយអោយគ្រួសារនិមួយៗ ជួបជុំគ្នាអធិស្ឋានក្នុងគ្រួសារ រាល់ថ្ងៃ ។
- ការដាស់តឿនរដ្ឋអំណាចស៊ីវិលអំពីបញ្ហា ដូចជាការយកកូនចេញ ការលែងលះប្តីប្រពន្ធ អំពើអាសអាភាស និង អំពីសង្គមដែលត្រូវការក្រិត្យវិន័យគ្រីស្តជនជាចាំបាច់ ។
- ការចាត់ចែងរបៀបគ្រប់គ្រងក្រុមជំនុំ ។
- ការរៀបចំធ្វើសកម្មភាព ដើម្បីប្រកបគ្នា ។
- ការចូលរួមសហការគ្នាចាត់ចែងប្រាក់ជង្វាយ និង ហិរញ្ញវត្ថុ ។
- ។ល។ និង ។ល។... ។

បើអាចធ្វើបាន ក្រុមបំពេញកិច្ចការបំរើនិមួយៗត្រូវកត់ត្រាទុកពី :

- អ្នកដឹកនាំរបស់ក្រុម ។
- គោលបំណងរបស់ក្រុម ។
- មនុស្សដែលធ្វើជាអ្នកដឹកនាំក្រុម ត្រូវរាយការណ៍ជូន ។
- គោលដៅ និង ក្រិត្យក្រមការងារ ។
- ទីកន្លែង និង ពេលវេលាប្រជុំរបស់ក្រុម ។
- អ្នកដែលត្រូវហាត់រៀនជាអ្នកដឹកនាំជំនួយ ដើម្បីអោយពួកគេអាចចាប់ផ្តើមក្រុមថ្មី ។

កំណត់ចំណាំ : ការបង្កើតសាវ័ក និង កម្មវិធីបង្ហាត់បង្រៀនដែលបានរៀបរាប់នៅក្នុងក្លូនសៀវភៅនេះ គឺសំរាប់សមាជិកទាំងអស់របស់ក្រុមជំនុំ ។ រីឯកម្មវិធី «បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត »វិញ សំរាប់តែសមាជិកដែលត្រូវបំពេញកិច្ចការឃ្វាលតែប៉ុណ្ណោះ ។

ការយកព្រះបន្ទូលទៅអនុវត្តផ្ទាល់នោះ ជួយអោយអ្នកងាយចងចាំជាង ។ ដើម្បីទន្ទេញខព្រះគម្ពីរ អ្នកត្រូវកត់ខនោះ ព្រមទាំងឈ្មោះសៀវភៅ លេខជំពូក និង លេខខ ហើយទន្ទេញអោយចាំជាមួយគ្នា ។ ដប់នាទីក្រោយ ត្រូវសូត្រខនោះឡើងវិញ រួចពិនិត្យមើលខនោះឡើងវិញ ។ មួយម៉ោងក្រោយ ត្រូវធ្វើដូចនេះម្តងទៀត ។ មួយអាទិត្យក្រោយ ធ្វើដូចនេះម្តងទៀត ហើយមួយខែក្រោយធ្វើដូចនេះម្តងទៀត ។ អ្នកប្រាកដជាចាំខព្រះគម្ពីរនោះជារៀងរហូត ។

គ្រីស្តជនខ្លះ បានរកឃើញថា បើទន្ទេញខគម្ពីរចំនួនដប់ពីរក្នុងមួយខែ នោះមានប្រយោជន៍ណាស់ ឱ្យអាចចាំខគម្ពីរចំនួន ១៤៤ ក្នុងមួយឆ្នាំ ។ បើអ្នកចង់ធ្វើដូចនេះ នៅទំព័របន្ទាប់មានក្រុមខគម្ពីរដប់ពីរក្រុម ដែលមួយក្រុមមានដប់ពីរខសំរាប់ទន្ទេញ ។

© Project WorldReach © SEAN

ខព្រះគម្ពីរសំរាប់ទន្ទេញ

អ្នកនិពន្ធទំនុកតម្កើងពោលថា÷ *«ទូលបង្គំរក្សាព្រះបន្ទូលរបស់ព្រះអង្គទុកនៅក្នុងចិត្ត ដើម្បីកុំអោយប្រព្រឹត្តអំពើបាបទាស់នឹងព្រះហឫទ័យព្រះអង្គ»* (ទំនុកតម្កើង ១១៩:១១) ។ ព្រះបន្ទូលព្រះជាម្ចាស់អប់រំយើងបានល្អបំផុត ។ *«ទូលបង្គំចេះដឹងជាងគ្រូៗទាំងប៉ុន្មានរបស់ទូលបង្គំទៅទៀត ដ្បិតទូលបង្គំយកដំបូន្មានទាំងប៉ុន្មានមកសញ្ជឹងគិត»* (ទំនុកតម្កើង ១១៩:៩៩) ។ អស់អ្នកដែលចង់រីកចំរើនឡើង ក្នុងជីវិតជាគ្រីស្តជន ត្រូវទន្ទេញខព្រះ-គម្ពីរ ។ គ្រីស្តជនច្រើនណាស់ ដែលត្រូវគេយកទៅដាក់ក្នុងមន្ទីរឃុំឃាំង ដោយសារពួកគេជឿលើព្រះគ្រីស្ត ហើយគេមិនអនុញ្ញាតិអោយមានព្រះគម្ពីរទៀត តែពួកគ្រីស្តជននៅតែអាចរិះគិតពិចារណាជាប្រចាំអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពីព្រោះពួកគេចាំព្រះបន្ទូលស្នាត់នៅក្នុងចិត្ត ។

គោលការណ៍ណែនាំ សំរាប់បណ្តុះបណ្តាល និង បង្ហាត់បង្រៀនក្រុមបំពេញកិច្ចការបំរើថ្មីមួយ

ឧទាហរណ៍ជាក់ស្តែងមួយ :

- **កំណត់រកសេចក្តីត្រូវការ ។**

  ព្រះជាម្ចាស់បានបណ្តាលចិត្តសមាជិកជាច្រើន ឱ្យគិតគូរអំពីកិច្ចការបំរើសំរាប់គ្រួសារបែកបាក់ យុវជនរឹងចចេសមិនស្តាប់បង្គាប់ និង មនុស្សចាស់ ។ សមាជិកទាំងនោះ អធិស្ឋានស្វែងរកព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយលើកយកគំនិតនេះ ទៅជំរាបជូនគ្រូគង្វាលដឹកនាំក្រុមជំនុំរបស់ពួកគេ ។ គ្រូគង្វាលយកយោបល់នេះ ទៅពិភាក្សាជាមួយក្រុមបំពេញកិច្ចការឃ្វាលរបស់គាត់ ហើយក្រុមឃ្វាលនោះគាំទ្រគំនិតផ្តួចផ្តើមនេះ ។ ក្រុមឃ្វាលចាត់តាំងអ្នកដឹកនាំម្នាក់ ដែលចេះគិតគូរពីកិច្ចការបំរើនេះ ហើយមានបទពិសោធន៍ក្នុងកិច្ចការឃ្វាល និង មានទឹកចិត្តពុះពារចង់បំពេញមុខងារបំរើនេះ ។

- **បង្ហាត់បង្រៀនពួកអ្នកជឿ ដែលមានអំណោយទាន សំរាប់ធ្វើកិច្ចការបំរើនេះ ។**

  អ្នកដឹកនាំជួបប្រជុំជាមួយសមាជិកឯទៀត ដែលចាប់អារ-ម្មណ៍អំពីកិច្ចការបំរើនេះ ហើយបណ្តុះបណ្តាលពួកគេអោយអាចបំពេញកិច្ចការបំរើនេះ ។ សមាជិកមួយចំនួនរបស់ក្រុមស្ម័គ្រចិត្តផ្តល់ដំបូន្មានដល់គ្រួសារ សមាជិកខ្លះទៀតយល់ព្រមធ្វើការជួយយុវជន និង មនុស្សចាស់ ។

- **ក្រុមជំនុំអធិស្ឋាន ចាត់តាំងពួកសមាជិកនៃក្រុមបំរើកិច្ចការនេះ ។**

  ក្រុមជំរាបជូនពតិមាន អំពីផែនការរបស់ពួកគេដល់ក្រុម-ជំនុំ ហើយពួកអ្នកដឹកនាំក្រុមជំនុំអធិស្ឋានអោយពួកគេទូលសូមឱ្យព្រះជាម្ចាស់ប្រទានព្រះពរដល់ការងាររបស់ពួកគេ ។ ក្រោយពីទទួលការអធិស្ឋានរួច ក្រុមសរសេរលិខិតអញ្ជើញ និង ជូនពិមានអំពីការនេះ ដើម្បីផ្ញើជូនអ្នកជិតខាង ។

- ទន្ទេញកាលបរិច្ឆេទសំខាន់ៗ ដូចជា :
  - លោកអប្រាហាំ : ២000 ឆ្នាំ មុនព្រះគ្រីស្ត (មុន គ.ស)
  - លោកម៉ូសេ : ១៤00 ឆ្នាំ មុន គ.ស
  - ស្តេចដាវីឌ : ១000 ឆ្នាំ មុន គ.ស
  - ការបែកបាក់របស់រាជាណាចក្រអ៊ីស្រាអែល (ស្រុកសាម៉ារី) : ៧២0 ឆ្នាំ មុន គ.ស
  - ការធ្លាក់ចុះរបស់រាជាណាចក្រយូដា (ក្រុងយេរូសាឡឹម) : ៥៨៧ ឆ្នាំ មុន គ.ស
  - ការកសាងព្រះវិហារនៅក្រុងយេរូសាឡឹមឡើងវិញ : ៥២0 ឆ្នាំ មុន គ.ស
  - ពួកជនជាតិរ៉ូម៉ាំងកំទេចក្រុងយេរូសាឡឹម : ឆ្នាំ ទី ៧0 នៃគ.ស ។

- សិក្សាព្រះគម្ពីរដោយខ្លួនឯង តាមរបៀបខ្លះខាងក្រោមនេះ ។
  - ☐ អានព្រះគម្ពីរទាំងមូលមួយឆ្នាំម្តង ។
  - ☐ ទន្ទេញ ខ ព្រះគម្ពីរ ។

© Project WorldReach © SEAN

- ប្រើសៀវភៅសមោធានព្រះគម្ពីរ ដើម្បីរកខព្រះគម្ពីរ ។
- ប្រើខព្រះគម្ពីរ ដើម្បីបង្ហាញថាព្រះយេស៊ូជាព្រះជាម្ចាស់ :

អេសាយ ៩:៦	ម៉ាថាយ ១:២៣ (ជាមួយនឹង
ម៉ាកុស ១៤:៥៣-៦៥	អេសាយ ៧:១៤)
យ៉ូហាន ១:១	យ៉ូហាន ១:១៤
យ៉ូហាន ១:៣	យ៉ូហាន ៨:៥៨ (ជាមួយនឹង
យ៉ូហាន ១៤:៩	សេរីភាព ៣:១៤)
កូឡូស ១:១៥	យ៉ូហាន ១០:៣០
	យ៉ូហាន ២០:២៨
	រ៉ូម ៩:៥

- រៀបចំរឿងក្នុងព្រះគម្ពីរជាឆាកល្ខោន ។ រឿងក្នុងព្រះគម្ពីរខ្លះ ដែលសមរម្យនឹងធ្វើជាឆាកល្ខោន គឺ :

កំណើតពិភពលោក ៣	កំណើតពិភពលោក ១៨
នាងរូថ	១ សាមូអែល ១៧
យ៉ូហាន ៦:១-២៤	យ៉ូហាន ៩
លូកា ១០:២៥-៣៦	លូកា ១៥:១១-៣១

- **ធ្វើអោយកិច្ចការបំរើនេះរីកចំរើនឡើង ។**

ពួកគេចាប់ផ្តើមទៅជួបគ្រួសារដែលមានទុក្ខលំបាកទាំងនោះ និង ផ្តល់អ្នបអាហារពិសេសដល់មនុស្សចាស់ ។ មិនបានប៉ុន្នានអាទិត្យផង គ្រួសារបាក់បែកជាច្រើនបានជានាគ្នាវិញ ។ លើសពីនេះទៅទៀត យុវជន និង មនុស្សចាស់ជាច្រើនចាប់ផ្តើមជឿលើព្រះយេស៊ូ និង មកចូលរួមជាមួយក្រុមជំនុំ ។

- **បន្តត្រួតពិនិត្យកិច្ចការបំរើនេះ ។**

គ្រូគង្វាលដឹកនាំក្រុមជំនុំ ជួបប្រជុំជាមួយសមាជិកក្រុម ពីរខែម្តង ដើម្បីវាយតម្លៃកិច្ចការបំរើរបស់ក្រុម ។ គ្រូគង្វាលលើកទឹកចិត្តសមាជិកក្រុម ហើយផ្តល់អត្ថបទសំរាប់អានដែលមានប្រយោជន៍សំរាប់កិច្ចការបំរើនេះ ។ គ្រូគង្វាល និងសមាជិកក្រុម ចែកចាយគំនិតគ្នា ដើម្បីដោះស្រាយបញ្ហា និងរៀបចំផែនការសំរាប់ពេលអនាគត ។

© Project WorldReach © SEAN

សង្ខេបគោលដៅចូលរួមធ្វើកិច្ចការបំរើ

គ្រូបង្រៀន :	**និស្សិត :**	**ខ្លឹមសារ :**	**គោលដៅ :**
អ្នកដែលដឹកនាំកិច្ចការបំរើមួយ ឬក្រុមបំពេញកិច្ចការបំរើមួយ ។	ពួកអ្នកដែលចូលរួមធ្វើកិច្ចការបំរើ ។	របៀបអនុវត្តកិច្ចការបំរើ ។	ពង្រឹងក្រុមជំនុំ និងសហគមន៍ ។



យោបល់អំពីការសិក្សាព្រះគម្ពីរអោយកាន់តែជ្រៅជ្រះ

សូមនឹកចាំថា ការយល់ដឹងព្រះបន្ទូលកាន់តែខ្លាំងឡើងៗ ត្រូវមានការស្រឡាញ់រាប់អានមនុស្សឯទៀត និង ការចេះបំរើដោយបន្ទាបខ្លួន ព្រមជាមួយដែរ (រ៉ូម ជំពូក ១២) ។

- ទន្ទេញឈ្មោះសៀវភៅរបស់សម្ពន្ធមេត្រីថ្មី និង សម្ពន្ធមេត្រីចាស់ តាមលំដាប់ ដើម្បីអាចរកឃើញដោយស្រួល ។
- រកឃើញទីកន្លែងសំខាន់ៗ នៅលើផែនទីព្រះគម្ពីរ និង រៀបរាប់ពីហេតុការណ៍ ដែលកើតឡើងនៅទីនោះ ។

  - ឧទាហរណ៍ក្នុងសម្ពន្ធមេត្រីថ្មី :

  ក្រុងយេរូសាឡឹម ភូមិបេថ្លេហិម ស្រុកណាសារ៉ែត សមុទ្រកាលីឡេ ទន្លេយ័រដាន់ ស្រុកយូដា ស្រុកសាម៉ារី ស្រុកកាលីឡេ ភូមិកាណា ក្រុងកាផាណុម ក្រុងដេកាប៉ូល ស្រុកក្រិក ក្រុងរ៉ូម ក្រុងអេភេសូ ។

  - ឧទាហរណ៍ក្នុងសម្ពន្ធមេត្រីចាស់ :

  ស្រុកអ្ងរ ប្រទេសអេស៊ីប ទីក្រុងបាប៊ីឡូន ទីក្រុងដាម៉ាស ទីក្រុងកាត ទីក្រុងយេរីខូ និង ភ្នំស៊ីណៃ ។

យើងកាន់តែមានសេចក្តីស្រឡាញ់ចំពោះអ្នកជឿឯទៀត ប៉ុន្តែ យើងក៏ត្រូវស្រឡាញ់រាប់អានអ្នកមិនទាន់ជឿ ព្រមទាំងជួយពួកគេ និង ផ្សាយដំណឹងល្អប្រាប់ពួកគេដែរ ។ ការធ្វើដូចនេះ ជួយក្រុម យើងកុំអោយគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន (យ៉ូហាន ៤:៣៥, កិច្ចការ ១៣:១-៣) ។

យើងកាន់តែមានជីវិតបរិសុទ្ធ និង កាន់តែចេះស្តាប់បង្គាប់ព្រះគ្រីស្ត ។ គុណសម្បត្តិគ្រីស្តជន ដែលយើងមាន ត្រូវបង្ហាញចេញជាការបំរើអ្នកដទៃ ។

តើយើងបង្រៀនអ្នកដទៃ ឱ្យធ្វើខ្លួនគេអោយក្លាយជាចាស់ទុំខាងព្រលឹងវិញ្ញាណផង និង ធ្វើឱ្យភាពចាស់ទុំរបស់ខ្លួនជួយកសាងអ្នកដទៃ អោយរីកចំរើនឡើងផង ដោយរបៀបណា ? យើងធ្វើជាគំរូ ។ បើយើងមានអំណោយទានរឹងមាំខាងបង្រៀន យើងធ្វើការងារជិតស្និទ្ធជាមួយអ្នកឯទៀត ដែលមានមុខងារបំរើផ្សេងៗទៀត ។ យើងធ្វើការងារបង្រៀនព្រះបន្ទូលជាមួយការផ្សាយដំណឹងល្អ ការជួយមនុស្សដែលខ្វះខាត នៅក្នុងសហគមន៍ និង មុខងារបំរើផ្សេងៗទៀត តម្រូវទៅតាមសម្ពន្ធមេត្រីថ្មី ។ យើងធ្វើអោយមុខងារបំរើរបស់យើង ស្រុះស្រួលស៊ីសង្វាក់ជាមួយមុខងារបំរើរបស់អ្នកឯទៀត ។

គោលដៅ ទី ៤ :

បានគ្រប់លក្ខណ៍ក្នុងអង្គព្រះគ្រីស្ត

(ការអនុវត្តតាមព្រះគម្ពីរ ដោយពឹងលើព្រះវិញ្ញាណដ៏វិសុទ្ធ)

គ្រីស្តជនអាចក្លាយជាចាស់ទុំខាងព្រលឹងវិញ្ញាណ ដោយសារការសិក្សាព្រះបន្ទូលព្រះជាម្ចាស់ និង រស់នៅដោយប្រតិបត្តិតាមព្រះបន្ទូលព្រះជាម្ចាស់ ។ យើងសិក្សាព្រះបន្ទូលព្រះជាម្ចាស់ ដើម្បីអោយអាចយល់ពីចរិតលក្ខណៈ សកម្មភាព ព្រះហឫទ័យ និង ផែនការរបស់ព្រះជាម្ចាស់ ។ បន្ទាប់មក យើងយកសេចក្តីពិតទាំងនោះ មកអនុវត្ត និង ប្រតិបត្តិតាមក្នុងការរស់នៅប្រចាំថ្ងៃរបស់យើង និង កិច្ចការបំរើរបស់យើង ។

មនុស្សខ្លះ ដែលបានចាប់ផ្តើមសិក្សាព្រះបន្ទូលព្រះជាម្ចាស់កាន់តែជ្រៅជ្រះ ច្រើនតែប្រហែសមិនខំធ្វើអោយចរិតលក្ខណៈរបស់ខ្លួនរីកចំរើន និង មិនចូលរួមធ្វើកិច្ចការបំរើទេ ។ បើការសិក្សាព្រះ-បន្ទូលព្រះជាម្ចាស់ មិននាំឱ្យមនុស្សកាន់តែមានសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ សេចក្តីស្រឡាញ់ចំពោះមនុស្សឯទៀត និង កាន់តែចូលរួមធ្វើកិច្ចការបំរើទេ ការសិក្សានោះគ្មានប្រយោជន៍ទេ ។ ចំណេះដឹងនាំឱ្យមនុស្សអួតបំប៉ោងខ្លួន តែសេចក្តីស្រឡាញ់កសាងមនុស្សអោយរីកចំរើនឡើង យោងទៅតាម ១ កូរិនថូស ៨:១ ។

យើងមិនអាចក្លាយជាអ្នកចាស់ទុំគ្រប់លក្ខណៈបានទេ នៅក្នុងលោកីយ៍នេះ ប៉ុន្តែ យើងអាចបន្តរីកចំរើនក្នុងអង្គព្រះគ្រីស្ត ។ ព្រះវិញ្ញាណដ៏វិសុទ្ធជួយយើង ពេលយើងអនុវត្តជំហាននិមួយៗ ។ សាវ័កប៉ូលមានប្រសាសន៍ថា៖ *«បងប្អូនអើយ ចំពោះរូបខ្ញុំផ្ទាល់ ខ្ញុំយល់ឃើញថា ខ្ញុំមិនទាន់បានទៅដល់ទីដៅនៅឡើយទេ ។ ខ្ញុំមានបំណងតែមួយ គឺបំភ្លេចអ្វីៗទាំងអស់ដែលខ្ញុំរត់ហួសមកហើយ ដើម្បីផ្ចង់ចិត្តឆ្ពោះទៅរកអ្វីៗ ដែលនៅខាងមុខ ។ ខ្ញុំរត់តំរង់ទៅរកទីដៅ ដើម្បីអោយបានទទួលរង្វាន់ពីព្រះជាម្ចាស់ ដែលទ្រង់បានត្រាស់ហៅយើងពីស្ថានបរមសុខ អោយទទួលរួមក្នុងអង្គព្រះគ្រីស្តយេស៊ូ»* (ភីលីព ៣:១៣-១៤) ។

ក្លាយជាគ្រីស្តជនខាងព្រលឹងវិញ្ញាណក្នុងព្រះគ្រីស្ត បានន័យថា យើងបានរីកចំរើនឡើង ដើម្បីអោយបានដូចព្រះអម្ចាស់យេស៊ូ ។ យើងមិនត្រូវរាស់ក៏រិតចាស់ទុំ ដោយសារកិរិតការយល់ដឹង ឬ កិរិតការងារក្រុមជំនុំ ដែលយើងធ្វើ ឬ រយៈពេលយើងអធិស្ឋាននោះទេ ។ គ្រីស្តជនមិនទាន់ចាស់ទុំខាងព្រលឹងវិញ្ញាណ ពុទ្ធសាសនិកជន និង អ្នកកាន់សាសនាហិណ្ឌូ ច្រើនតែអនុវត្តលំហាត់ខាងព្រលឹងវិញ្ញាណទាំងនេះ ដូចជាបង្កើនការយល់ដឹង ខិតខំធ្វើការងារក្រុមជំនុំ អធិស្ឋាន ។ល។) ។

ក្លាយជាចាស់ទុំខាងព្រលឹងវិញ្ញាណ មិនមែនបានន័យថា យើងរីកចំរើនរឹងមាំ ក្នុងគ្រប់ផ្នែកទូទៅនៃកិច្ចការបំរើនោះទេ ។ ប៉ុន្តែ ក្លាយជាចាស់ទុំខាងព្រលឹងវិញ្ញាណ ជាការប្រើប្រាស់អំណោយទានដែលព្រះជាម្ចាស់ប្រទានអោយយើង អោយស៊ីសង្វាក់ជាមួយអ្នកជឿឯទៀត ដែលមានអំណោយទានផ្សេងពីយើង ។ គ្មានអ្នកណាម្នាក់ជាអ្នកជើងឯកទេ តែទាំងអស់គ្នាធ្វើកិច្ចការថ្វាយព្រះជាម្ចាស់រួមគ្នា យោងទៅតាមតួនាទីផ្សេងៗ និង អំណោយទានដែលព្រះជាម្ចាស់បានប្រទានអោយម្នាក់ៗ ។ ម៉្យាងទៀត ការយល់ដឹងកាន់តែច្រើន កាន់តែជំនាញក្នុងការងារ និង កាន់តែបរិសុទ្ធឡើង មិនមែនគ្រាន់តែសំរាប់ធ្វើឱ្យខ្លួនយើងប្រសើរឡើងប៉ុណ្ណោះទេ ប៉ុន្តែ សំរាប់កសាងពង្រឹងមនុស្សឯទៀតដែរ (១ កូរិនថូស ជំពូក ១២-១៣) ។

ការស្គាល់ដឹងពីព្រះគ្រីស្ត និង ព្រះបន្ទូលកាន់តែខ្លាំងឡើងៗ ត្រូវមានការស្រឡាញ់រាប់អានមនុស្សឯទៀត និង ការចេះបំរើ ដោយបន្ទាបខ្លួន ព្រមជាមួយដែរ (រ៉ូម ជំពូក ១២) ។

យើងកាន់តែជំនាញធ្វើកិច្ចការបំរើ ប៉ុន្តែ យើងក៏ខិតខំលើកទឹកចិត្ត និង បង្ហាត់បង្រៀនគ្រីស្តជនឯទៀត ដែលមិនទាន់មានបទពិសោធន៍ផងដែរ ដើម្បីឱ្យពួកគេជំនាញធ្វើកិច្ចការបំរើដែរ (ទីតុស ១:៥) ។